# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៨ អនក្រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ឆេង សារឿន** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ទទួលបន្ទុកជាអគ្គលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **ម៉ុន ហ៊ាន** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម **គោស៊ុំ សារឿត** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៥- ឯកឧត្តម **សួង ចាន់ថន** | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៦- ឯកឧត្តម **ឡុញ ហ៊ាល** | អគ្គនាយកបច្ចេកទេស នៃក្រសួងបរិស្ថាន | សមាជិក |
| ៧- ឯកឧត្តម **ផៃ ផាន** | អភិបាលរងខេត្តព្រះសីហនុ | សមាជិក |
| ៨- លោក **ហាក់ ម៉ុណ្ណារ៉ាក់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- លោក **ជា សំអាង** | អនុប្រធានរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

| | | | |
|---|---|---|---|
| ១០- លោក | **យុន ហោ** | ប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- លោក | **តន់ សុខជា** | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២- លោក | **មុជ ឈុនហ៊ិន** | ប្រធាននាយកដ្ឋានវារីអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៣- លោក | **សុទ្ធ ធី** | ប្រធាននាយកដ្ឋានបូកសរុបព័ត៌មានវិទ្យានិងទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៤- លោក | **សុខ ផន** | នាយរងទី១ខុទ្ទកាល័យសាលាខេត្តព្រះសីហនុ | សមាជិក |

**ប្រការ ២ :** គណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ មានភារកិច្ចដូចខាងក្រោម ÷

- ផ្តល់ការណែនាំជាទូទៅក្នុងការអនុវត្តគម្រោងថ្មី និងគម្រោងនានា ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ក្នុងតំបន់ទីជម្រាលក្បាលឆាយខេត្តព្រះសីហនុ សំដៅគ្រប់គ្រងដោយនិរន្តរភាពនៃតំបន់ទីជម្រាលក្បាលឆាយ
- ធ្វើការសម្របសម្រួលជាមួយម្ចាស់គម្រោង និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តគម្រោងនានាក្នុងតំបន់ទីជម្រាលក្បាលឆាយ ប្រព្រឹត្តទៅដោយរលូន គ្មានឧបសគ្គ និងសម្រេចបានជោគជ័យ
- សិក្សា វាយតម្លៃផលប៉ះពាល់ជាទូទៅចំពោះតំបន់ទីជម្រាលក្បាលឆាយទាំងមូល និងជំរុញការសហការរវាងអង្គភាព ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាការគ្រប់គ្រងប្រកបដោយនិរន្តរភាព តំបន់ទីជម្រាលក្បាលឆាយ ។

**ប្រការ ៣ :** សេចក្តីសម្រេចលេខ ០៦ សសរ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារសិក្សាវាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ក្រុងព្រះសីហនុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលខេត្តព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*